**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# AIA សម្រាប់កូន ដំណោះស្រាយថ្មី ផ្តោតសំខាន់លើការអប់រំរបស់កូនៗ និងផ្តល់ភាពស្ងប់ចិត្តជូនឪពុកម្តាយ

ភ្នំពេញ 11-13 មីនា 2022 ៖ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនស្ទួរេន ម.ក (អេ អាយ អាយ ខេមបូឌា) នឹងជួយឪពុកម្តាយគ្រប់រូបធ្វើការកំណត់មូលដ្ឋានគ្រឹះដ៏ល្អបំផុតឲ្យកូនៗជាមួយ **AIA សម្រាប់កូន** ដែលជាដំណោះស្រាយថ្មីដ៏ទូលំទូលាយ និងបត់បែន ក្នុងការផ្តល់ការធានាលើប្រាក់សម្រាប់ការសិក្សាពេលអនាគតរបស់កូនៗជាទីស្រឡាញ់។

ផលិតផលនេះបង្កើតឡើងជាពិសេស ដើម្បីធានាការអប់រំរបស់កូនៗចាប់ពីថ្នាក់បឋមសិក្សា រហូតដល់សាកលវិទ្យាល័យ ក៏ដូចជាសម្រាលបន្ទុកហិរញ្ញវត្ថុក្នុងករណីដែលឪពុកម្តាយទទួលមរណភាព ឬ ពិការទាំងស្រុង និងជាអចិន្ត្រៃយ៍ ។ ផលិតផលនេះពិតជាផ្តល់សន្តិភាពផ្លូវចិត្តផ្នែកហិរញ្ញវត្ថុជូនឪពុកម្តាយ ហើយពួកគាត់អាចផ្តោតអារម្មណ៍ និងតាមដានលើការសិក្សារបស់កូនតែប៉ុណ្ណោះ ។

**អេ អាយ អេ ខេមបូឌា** បានសម្ពោធជាផ្លូវកាផលិតផល **AIA សម្រាប់កូន** ក្នុងផ្សារទំនើប AEON ភ្នំពេញ កាលពីថ្ងៃទី១១ ដល់ថ្ងៃទី ១៣ ខែមីនា កន្លងទៅនេះ។ ក្នុងអំឡុងពេល៣ថ្ងៃនោះ ក្រុមហ៊ុនទទួលបានការគាំទ្រ និងចូលរួមយ៉ាងសប្បាយរីករាយពីសំណាក់ឪពុកម្តាយ និងកូនជាច្រើន។ យើងសង្កេតឃើញថាមានឪពុកម្តាយ និងកូនៗប្រមាណជាង៤៥០០នាក់ បានចូលរួមក្នុងកម្មវិធីដើម្បីះពិភាក្សា និងស្វែងយល់បន្ថែមអំពីផលិផលថ្មីនេះ ការរៀបចំផែនការរៀនសូត្រនៅសាកលវិទ្យាល័យឯបរទេស លេងហ្គេមអប់រំសប្បាយៗ និងសកម្មភាពកម្សាន្តជាច្រើនផ្សេងទៀត ។

**AIA សម្រាប់កូន** ផ្តល់អត្ថប្រយោជន៍រួមមាន៖ ទឹកប្រាក់មួយកញ្ចប់សម្រាប់ធានាលើថ្លៃសិក្សា ទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន និងការបង់ជាសាច់ប្រាក់ចំនួនបី(៣)ដងដើម្បីអបអរព្រឹត្តិការណ៍សំខាន់ៗនៃការអប់រំដូចជាការបញ្ចប់ការសិក្សាកូន។ មួយវិញទៀត ប្រសិនបើឪពុកម្តាយដែលជាអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ រាល់បុព្វលាភធានារ៉ាប់រងត្រូវបង់ទាំអស់នឹងត្រូវលើកលែង ហើយអត្ថប្រយោជន៍លើការសិក្សានឹងកើនឡើងទ្វេដង ។

ផលិតផលនេះក៏ផ្តល់ភាពងាយស្រួល និងបត់បែនជូនឪពុកម្តាយក្នុងការរៀបចំផែនការសន្សំសម្រាប់គោលដៅផ្សេងៗ ដូចជា៖ ទិញអចលនទ្រព្យ យានយន្ត ដើមទុនសម្រាប់ចាប់ផ្តើមអាជីវកម្ម ឬ ទុកជាកេរដំណែលសម្រាប់កូន ឬចៅ។

ផលិតផលនេះមាន ៤ជម្រើសក្នុងការបង់បុព្វលាភធានារ៉ាប់រងគឺ ៥ឆ្នាំ ១០ឆ្នាំ ១៥ឆ្នាំ និង ១៨ឆ្នាំ ហើយមានរយ:ពេលធានារ៉ាប់រងចាប់ពី ១៥ឆ្នាំ រហូតដល់ ២២ឆ្នាំ។ ឪពុកម្តាយក៏អាចបង្កើនការការពាររបស់ខ្លួនដោយបង់បន្ថែមបន្តិចបន្តួចដើម្បីទទួលបានអត្ថប្រយោជន៍ការពារលើជំងឺធ្ងន់ធ្ងរ និង ការចំណាយសម្រាកក្នុងមន្ទីរពេទ្យ។

លោក Andrew Loh អគ្គនាយកប្រតិបត្តិក្រុមហ៊ុន **អេ អាយ អេ ខេមបូឌា** បានមានប្រសាសន៍ថា៖ «**AIA សម្រាប់កូន** គឺស្របជាមួយគោលបំណងរបស់យើងក្នុងការជួយឲ្យប្រជាជនកម្ពុជារស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរដោយជួយឪពុកម្តាយគ្រប់រូបអាចផ្តល់អាទិភាពដល់ការអប់រំរបស់កូនៗទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

នេះគឺជាមូលដ្ឋានសំខាន់ក្នុងការផ្តល់ឲ្យកូនៗនូវចំណេះដឹង និងជំនាញកសាងខ្លួនឲ្យកាន់តែប្រសើរទាំងរាងកាយ សង្គម និង សេដ្ឋកិច្ច ដើម្បីឲ្យពួកគេរីកចម្រើនទៅជាមនុស្សពេញវ័យប្រកបដោយសមត្ថភាព គួរឲ្យកោតសរសើរ ។

«នៅពេលដែលផលិតផលរបស់យើងត្រូវបានបង្កើតឡើងដើម្បីផ្តល់ការធានាហិរញ្ញវត្ថុការអប់រំ វាក៏ជួយឲ្យឪពុកម្តាយអាចផ្តោតអារម្មណ៍តែលើការសិក្សារបស់កូនៗ ដោយមិនពុំមានក្តីបារម្ភពីបញ្ហាហិរញ្ញវត្ថុដែលអាចរារាំងដល់កូនៗមិនឲ្យទទួលបានសក្តានុពលពេញលេញរបស់ពួកគេ»។

**AIA សម្រាប់កូន** ជាផលិតផលមួយក្នុងចំណោមផលិតផលថ្មីៗដែលក្រុមហ៊ុនទើបតែបានសម្ពោធដូចជា៖ **AIA និវត្តន៍** ជាផលិតផលដែលផ្តល់ដំណោះស្រាយធានារ៉ាប់រងរហូតដល់អាយុ១០០ឆ្នាំ **AIA ងាយៗលឿនៗ** ដែលជាដំណោះស្រាយទទួលយកការធានារ៉ាប់រងតាមប្រព័ន្ធ Online ដោយអតិថិជនអាចទិញផលិតផលដែលមានតម្លៃសមរម្យដូចជា **AIA 3ការពារCovid-19** **AIA សុវត្ថិភាពទ្រព្យ** និងផលិតផលផ្សេងៗទៀត។

សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ឲ្យកូនរបស់លោកអ្នកនូវអ្វីដែលល្អបំផុតសម្រាប់ចាប់ផ្តើមអនាគតដ៏ភ្លឺស្វាងជាមួយ AIA **សម្រាប់កូន** សូមទាក់ទងសេវាកម្មអតិថិជនរបស់ **អេ អាយ អេ** តាមរយៈលេខទូរស័ព្ទ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh

**អំពី អេ អាយ អេ គ្រុប**

អេ អាយ អេ គ្រុប លីមីតធីត និង សាខា (តទៅហៅថា អេ អាយ អេ “AIA” ឬ គ្រុប “Group”) មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។
ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ នៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅចិនដីគោក ទីក្រុងហុងកុង SAR(១) ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី អូស្ត្រាលី កម្ពុជា ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ញ៉ូហ្ស៊ីលែន ហ្វីលីពិន កូរ៉េខាងត្បូង ស្រីលង្កា តៃវ៉ាន់(ចិន) វៀតណាម ប្រ៊ុយណេ ម៉ាកាវSAR(២) និង ក្រុមហ៊ុនបណ្តាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។

ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ អេ អាយ អេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃកាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្តោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និង មានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសរុបចំនួន ៣៤០ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

អេ អាយ អេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ពលរដ្ឋទូទៅតាមរយៈការផ្តល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងអាយុជីវិតធានារ៉ាប់រងលើគ្រោះថ្នាក់ ធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ គ្រុបក៏ផ្តល់ដំណោះស្រាយអត្ថប្រយោជន៍សម្រាប់បុគ្គលិក ធានារ៉ាប់រងឥណទាន និង សេវាកម្មប្រាក់សោធនិវត្តន៍ជូនដល់និយោជក ។ តាមរយៈបណ្តាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេ អាយ អេ បានផ្តល់ការការពារដល់ម្ចាស់បណ្ណសន្យារ៉ាប់រងជារូបវន្តបុគ្គលច្រើនជាង ៣៩ លាននាក់ និងសមាជិកដែលបានចូលរួមក្នុងគម្រោងបណ្ណសន្យារ៉ាប់រងជាក្រុមជាង ១៦ លាននាក់។

អេ អាយ អេ គ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃ គណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ “១២៩៩” ស្របតាមច្បាប់ស្តីពីការទទួលប្រាក់តម្កល់នៃសហរដ្ឋអាមេរិក (កម្រិត ១) A (American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា៖ “AAGIY”)។

*សំគាល់៖*

*១. ទីក្រុងហុងកុងSAR  គឺសំដៅទៅលើតំបន់រដ្ឋបាលពិសេសនៃទីក្រុងហុងកុង*

*២. ម៉ាកាវ SAR គឺសំដៅទៅលើតំបន់រដ្ឋបាលពិសេសនៃម៉ាកាវ*